ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៣
## និងទិសដៅការងារឆ្នាំ២០១៤ របស់ធនាគារជាតិនៃកម្ពុជា
## រាជធានីភ្នំពេញ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៤

**សូមគោរព :**

- **គណៈអធិបតី!**
- **លោក Arnaud de Villepoix ជំនាញការទូទៅប្រចាំធនាគារជាតិនៃកម្ពុជា!**
- **លោក Robert Beerens ជំនាញការប្រចាំធនាគារជាតិនៃកម្ពុជា!**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

នៅពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ២០១៤ របស់ធនាគារជាតិនៃកម្ពុជាយើង បានឈានដល់ទីបញ្ចប់ប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាលបំផុត ។ ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា សមាជិក-សមាជិកានៃអង្គសន្និបាតយើងពិតជាក្តាប់បាននូវខ្លឹមសារសំខាន់ៗ អនុសាសន៍ណែនាំជាយុទ្ធសាស្ត្រ និងទិសដៅការងារនៅឆ្នាំ២០១៤ សម្រាប់យកទៅអនុវត្តបន្តទៀត ។ ជាមួយគ្នានេះ ខ្ញុំជឿជាក់ថាមន្ត្រីបុគ្គលិកយើងក៏បានស្វែងយល់ពីការអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារនិងហិរញ្ញវត្ថុ ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា និងជាពិសេស អនុសាសន៍ថ្មីៗ របស់ថ្នាក់ដឹកនាំយើងសម្រាប់ដោះស្រាយបញ្ហាប្រឈមនានាផងដែរ ។ ទាំងនេះសុទ្ធតែជាគំនិតនិងទស្សនៈបន្ថែម សម្រាប់មន្ត្រីបុគ្គលិកយើងទាំងអស់គ្នាយកទៅបំពេញការងារដោយរលូន ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានធ្វើបទអន្តរាគមន៍និងផ្តល់អនុសាសន៍ល្អៗ ជូនអង្គសន្និបាតយើង ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកទាំងអស់ដែលបានអញ្ជើញចូលរួមនិងខិតខំយកចិត្តទុកដាក់ស្តាប់ខ្លឹមសារសំខាន់ៗនៃអង្គសន្និបាត ដើម្បីយកទៅបំពេញភារកិច្ចឱ្យចំគោលដៅ និងកាន់តែទទួលបានជោគជ័យល្អប្រសើរថែមទៀត ។



ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ខ្ញុំបានកត់សម្គាល់ឃើញថា ក្នុងរយៈពេលពីរថ្ងៃនេះ អង្គសន្និបាតរបស់យើងបាន ប្រព្រឹត្តទៅយ៉ាងសកម្ម ដោយផ្តោតលើចំណុចសំខាន់ៗ ដូចតទៅ ៖

**១/- សមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជា និងស្ថានភាពសេដ្ឋកិច្ចជាតិ ៖** កាលពីម្សិលមិញនេះ លោកជំទាវ ជា សិរី បានជម្រាបជូនអង្គសន្និបាត ពីសមិទ្ធផលដែលធនាគារជាតិនៃកម្ពុជាបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចរួចហើយ ដូចជា សមិទ្ធផលនៃការដឹកនាំនិងគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ ការត្រួតពិនិត្យនិងពង្រឹងសុវត្ថិភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងការវិនិយោគទុនបម្រុងអន្តរជាតិ ការគ្រប់គ្រងនិងពង្រឹងសុវត្ថិភាពប្រតិបត្តិការការងារធនាគារកណ្តាល ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាដើម ។ សមិទ្ធផលទាំងអស់នេះ ពិតជាបានរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព រក្សាបាននូវស្ថិរភាពថ្លៃ និងបានរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រចីរភាពនៃកំណើនសេដ្ឋកិច្ច ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ។

ជាទិសដៅនៅពេលខាងមុខ ដើម្បីសម្រេចបាននូវគោលដៅចីរភាពនៃកំណើន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល តម្រូវឱ្យអាជ្ញាធរពាក់ព័ន្ធត្រូវរួមចំណែកបន្តពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអនុវត្តគោលនយោបាយគាំទ្រមួយចំនួនទៀត ដូចជាការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ដោយផ្សារភ្ជាប់នឹងទីផ្សារជាដើម ។ ចំពោះវិស័យធនាគារ ខ្ញុំសូមលើកឡើងនូវមតិខ្លះៗសម្រាប់ឱ្យមន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្ត ជ្រាបពីអ្វីដែលធនាគារជាតិនៃកម្ពុជាត្រូវធ្វើនាពេលអនាគត ដូចតទៅ ៖

**២/- ចំពោះការងារគណនេយ្យ IT និងប្រព័ន្ធទូទាត់** ៖ ដូច លោក អ៊ូ ចាន់តារា បានបញ្ជាក់ហើយថា ការងារនេះ មានការវិវត្តរីកចម្រើនជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ព្រោះថាការងារបច្ចេកទេសគឺតម្រូវឱ្យយើងរៀនបណ្តើរធ្វើការងារបណ្តើរ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទោះបីជាជួបការលំបាកក៏ដោយ ក៏យើងអាចជម្នះការលំបាកបាន ដោយអន្លើនិងជោគជ័យជាប់ជាប្រចាំ ។ ជាបទពិសោធន៍ល្អ ការអនុវត្តប្រព័ន្ធ Flexcube កន្លងមកបានបង្រៀនមន្ត្រីយើងពីរបៀបធ្វើការងារថ្មី ដែលមានលក្ខណៈវិទ្យាសាស្ត្រជាងមុន ពោលគឺបានប្តូរពីរបៀបធ្វើការពី Manual ទៅប្រើប្រព័ន្ធកុំព្យូទ័រទាំងអស់ ។ បច្ចុប្បន្ននេះ យើងកំពុងដំណើរការការងារគ្រប់គ្រងប្រព័ន្ធទូទាត់ ដែលជាតួនាទីសំខាន់របស់ធនាគារជាតិនៃកម្ពុជា ហើយក៏ជាការងារថ្មី ដែលយើងកំពុងដំណើរការសម្រាប់ទូទាត់តែមូលប្បទានបត្រផងដែរ ។ បច្ចុប្បន្ននេះ ប្រតិបត្តិការទូទាត់សងប្រាក់មានដូចជា មូលប្បទានបត្រ ការបញ្ជាទូទាត់ Credit Card, Debit Card, ATM, Easy Cash និងការទូទាត់តាមទូរសព្ទចល័តជាដើម កំពុងមានការរីកចម្រើនយ៉ាងខ្លាំងនៅកម្ពុជា ទាំងផ្នែកបណ្តាញសេវា និងផលិតផលហិរញ្ញវត្ថុ ។

ថ្មីៗនេះ យើងបានដាក់ឱ្យដំណើរការមូលបត្រប្រាក់បញ្ញើអាចជួញដូរបាន (NCD) ហើយនឹងមានឧបករណ៍ហិរញ្ញវត្ថុថ្មីៗថែមទៀត ដូចជា សញ្ញាបណ្ណនិងសន្លឹកហ៊ុនជាដើម ។ ដើម្បីពង្រឹងប្រតិបត្តិការទូទាត់នេះ យើងបានបំពាក់ប្រព័ន្ធ Client Module សម្រាប់ប្រព័ន្ធទូទាត់ដែលមានលក្ខណៈមជ្ឈការ និងបណ្តុះបណ្តាលមន្ត្រីជំនាញពីវិធីប្រើប្រាស់ប្រព័ន្ធនេះ ដល់ធនាគារជាសមាជិកសភាផាត់ទាត់ជាប់ជាប្រចាំ ។

ដើម្បីអនុវត្តការងារនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ខ្ញុំស្នើសុំឱ្យនាយកដ្ឋានជំនាញដូចជា នាយកដ្ឋានគណនេយ្យសហការជាមួយអគ្គាធិការដ្ឋាន នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀត ដើម្បីបន្តបណ្តុះបណ្តាលមន្ត្រីជំនាញរបស់ខ្លួន ទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្តជាប់ជាប្រចាំ ដើម្បីណែនាំពីរបៀបប្រើប្រាស់ (User guides) ការប្រើប្រាស់ប្រព័ន្ធទូទាត់ផ្ទាល់ ជាលក្ខណៈអន្តរធនាគារ រវាងធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភ្នាក់ងារប្រតិបត្តិផ្សេងទៀត ។

**៣/- ការពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារ ៖** ឯកឧត្តម គិម វ៉ាដា បានជម្រាបជូនអង្គសន្និបាតរួចហើយ អំពីការរីកចម្រើននៃវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ជាពិសេសអំពីវិធានការនិងវិធីសាស្រ្តថ្មីៗដែលយើងអនុវត្ត ដើម្បីពង្រឹងសុខភាពនិងសុវត្ថិភាពប្រព័ន្ធធនាគារនៅកម្ពុជា ។ សុវត្ថិភាពនៃប្រព័ន្ធធនាគារ គឺជាការងារអាទិភាពដែលយើងត្រូវពង្រឹងជាប់ជាប្រចាំតាមរយៈការដាក់ចេញនូវវិធានការទាំងផ្នែកម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្ន ដើម្បីត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ជាពិសេស គ្រឹះស្ថានណាដែលមានហានិភ័យជាប្រព័ន្ធ ។ ដើម្បីអនុវត្តការងារនេះឱ្យបានសម្រេច ធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នកម្មប្រព័ន្ធវិភាគរបាយការណ៍របស់ខ្លួន ទៅជាប្រព័ន្ធត្រួតពិនិត្យលើឯកសារ (OSSS) តាមប្រព័ន្ធកុំព្យូទ័រវិញ ។

នេះជា ប្រព័ន្ធត្រួតពិនិត្យថ្មីដែលជាយុទ្ធសាស្រ្តត្រួតពិនិត្យផ្អែកលើមូលដ្ឋានហានិភ័យ (Risk-based) ដែលផ្តោតជាសំខាន់ទៅលើការត្រួតពិនិត្យទិន្នន័យហិរញ្ញវត្ថុ ការបញ្ជូនរបាយការណ៍តាមប្រព័ន្ធ internet ការវិភាគស្ថានភាពហិរញ្ញវត្ថុនិងហានិភ័យ សាវតារធនាគារ និងវិធានការកែតម្រូវជាបន្ទាន់ ។ ទន្ទឹមជាមួយគ្នានេះ យើងក៏ត្រូវបន្តលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករ និងរៀបចំវិធីសាស្រ្តនៃការត្រួតពិនិត្យដោយផ្អែកលើទស្សនៈអនាគត (Forward-looking) និងការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ (Risk-Based Supervision) បន្ថែមលើយន្តការត្រួតពិនិត្យបច្ចុប្បន្ន ក្នុងខណៈពេលដែលវិស័យធនាគារមានការរីកចម្រើនខ្លាំងទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ព្រមទាំងវិស័យហិរញ្ញវត្ថុមិនមែនធនាគារកំពុងលេចចេញជារូបរាងឡើងផងដែរ ។

ចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញ មានការអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំង ហើយត្រូវបានរាជរដ្ឋាភិបាលទទួលស្គាល់ថាជាតួនាទីដ៏សំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ជាពិសេសក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ។ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសជាង ៣០ ដែលបានបង្កើតយុទ្ធសាស្ត្រជាតិស្តីពីមីក្រូហិរញ្ញវត្ថុ ។ ក្នុងចំណោមប្រទេសទាំងនេះ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សនិងត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដោយសារកម្ពុជាមានក្របខ័ណ្ឌបទប្បញ្ញត្តិនិងការត្រួតពិនិត្យលើការគ្រប់គ្រងអ្នកផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ។ បច្ចុប្បន្ននេះ ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើង និងបានពង្រីកសកម្មភាពរបស់ខ្លួនរហូតដល់អាចទទួលប្រាក់បញ្ញើ សម្រាប់បម្រើប្រជាពលរដ្ឋដែលមានចំណូលទាបទៀតផង ។ ក្រៅពីការពង្រឹងការងារត្រួតពិនិត្យជាប់ជាប្រចាំនោះ ត្រូវរៀបចំផែនការសកម្មភាពឱ្យស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែង ដូចជា ៖

១/- បង្កើនប្រសិទ្ធភាពតួនាទីការិយាល័យព័ត៌មានឥណទាន

២/- កែលម្អក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

៣/- បង្កបរិយាកាសប្រកួតប្រជែងលើអត្រាការប្រាក់ សេវានិងផលិតផលហិរញ្ញវត្ថុ

៤/- ពង្រីកលទ្ធភាពទទួលបានឥណទាន ចំពោះប្រជាជនដែលមានចំណូលទាបនៅតំបន់ជនបទបន្ថែមទៀត និង

៥/- សម្របសម្រួលគោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេស ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**៤/- ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** : គឺជាការងារសំខាន់របស់យើងក្នុងការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងសុវត្ថិភាពធនាគារកណ្តាល ។ ខ្ញុំសូមឯកភាពតាមមតិលោកជំទាវ ស្រី ស៊ីយុត ដែលបានជម្រាបជូនអង្គសន្និបាតយើង ។ ដើម្បីបន្តអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថែមទៀត ខ្ញុំស្នើសុំឱ្យអគ្គាធិការដ្ឋានបន្តចុះតាមដាន អនុវត្តតាមអនុសាសន៍ដែលបានលើកឡើង និងរៀបចំយន្តការវាយតម្លៃហានិភ័យប្រតិបត្តិការតាមផ្នែក និងពង្រឹងការងារអធិការកិច្ចទាំងនៅទីស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្ត បន្តទៀត ។ ខ្ញុំសូមបញ្ជាក់ថា ការងារនេះមានសារៈសំខាន់ណាស់សម្រាប់វាយតម្លៃពីភាពរឹងមាំ សុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ស្របតាមគោលការណ៍អភិបាលកិច្ចល្អ ។ ចំណុចដែលខ្ញុំបានលើកឡើងនេះ គឺទាក់ទងនឹងប្រសិទ្ធភាពប្រតិបត្តិការ និងសុវត្ថិភាពធនាគារកណ្តាលទាំងអស់ ។

ដើម្បីអនុវត្តការងារនេះប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមន្ត្រីបុគ្គលិកយើងត្រូវខិតខំអភិវឌ្ឍខ្លួនតាមរយៈការសិក្សាស្វែងយល់ពីការប្រែប្រួលនៃក្របខ័ណ្ឌនិងគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង ហើយម្យ៉ាងទៀតត្រូវខិតខំគោរពវិន័យការងារ គោរពការចាត់តាំង និងជំនាញមុខងារភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

**៥/-ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** : លោកជំទាវ សាយ សំអាត បានជម្រាបជូន ហើយខ្ញុំសូមឯកភាព ។ ដើម្បីអនុវត្តការងារនេះឱ្យបានជោគជ័យថែមទៀត យើងត្រូវខិតខំបណ្តុះបណ្តាលមន្ត្រីយើងលើផ្នែកជំនាញឯកទេសច្បាប់ជាតិផង ច្បាប់អន្តរជាតិផង សន្ធិសញ្ញាជាតិនានាផង និងជាពិសេស ពង្រឹងយន្តការសហការអនុវត្តច្បាប់ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពង្រឹងកិច្ចសហការជាមួយសហគមន៍ជាតិ-អន្តរជាតិបន្ថែមទៀត ដើម្បីរួមចំណែកការពារ ទប់ស្កាត់ និងប្រឆាំង រាល់សកម្មភាពនៃការលាងសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ។

ទន្ទឹមពេលជាមួយគ្នា យើងត្រូវបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាមិត្តក្នុងតំបន់ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលបរទេសក្នុងតំបន់ ដើម្បីបណ្តុះបណ្តាលឯកទេសកម្មដល់មន្ត្រីជំនាញ ផ្លាស់ប្តូរបទពិសោធន៍គ្នា និងធ្វើការស្រាវជ្រាវអំពីដំណោះស្រាយចំពោះបញ្ហាប្រឈមនានា ដែលកំពុងតែកើតឡើងនៅក្នុងតំបន់និងពិភពលោកនាពេលបច្ចុប្បន្ន ។

**៦/- ការងារអគ្គបេឡា** : ឯកឧត្តម ថា យ៉ាវ បានជម្រាបជូនអង្គសន្និបាតពីសមិទ្ធផលនៃការគ្រប់គ្រងបេឡាប្រតិបត្តិការ ការផ្គត់ផ្គង់ធនបត្រ ការរក្សាសុវត្ថិភាពឃ្លាំងទ្រព្យសម្បត្តិ និងការដឹកជញ្ជូនធនបត្រ ។ ការងារឃ្លាំងបេឡា គឺជាការងារបច្ចេកទេស ទាក់ទងនឹងការបោះផ្សាយ ការគ្រប់គ្រងឃ្លាំងបេឡា និងការតាមដានបរិមាណរូបិយវត្ថុទូទៅ នៅក្នុងសេដ្ឋកិច្ច ។ ដូច្នេះ ការងារនេះទាមទារនូវចំណេះដឹងទាំងផ្នែកជំនាញ ស្មារតីទទួលខុសត្រូវភាពស្មោះត្រង់និងការតស៊ូអត់ធ្មត់ចំពោះការងារ ។

ចំពោះការពង្រឹងវិន័យការងារ ខ្ញុំសូមឯកភាពតាមមតិណែនាំរបស់ ឯកឧត្តម ថា យ៉ាវ ផងដែរ ។ ការងាររបស់យើងរីកចម្រើននិងជោគជ័យកន្លងមក គឺតម្រូវឱ្យមន្ត្រីគោរពវិន័យការងារ មានភាពស្មោះត្រង់ និងមានការទទួលខុសត្រូវ ។ ដូច្នេះ ខ្ញុំស្នើសុំឱ្យប្រធាននាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាទាំងអស់ ត្រូវពង្រឹងវិន័យការងារ ក្នុងម៉ោងការងារ ជាពិសេស ការចេញ-ចូលក្នុងពេលបំពេញការងារស្នូល ដើម្បីបង្កើននូវប្រសិទ្ធភាពការងារ ។

**៧/- សមាគមមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា** ៖ កាលពីព្រឹកមិញនេះ តំណាងមន្ត្រីបុគ្គលិកយើងបានបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំសមាគមធនាគារជាតិនៃកម្ពុជាយើង ។ ជាលទ្ធផល អង្គសន្និបាតបានជ្រើសតាំងបេក្ខជនចំនួន ១៧ រូប ។ កម្មវិធីបោះឆ្នោតបានប្រព្រឹត្តទៅដោយសម្ងាត់ រលូន និងជោគជ័យ ។ ជាថ្មីម្តងទៀត ខ្ញុំសូមអបអរសាទរនិងជូនពរដល់ថ្នាក់ដឹកនាំនិងសមាជិកសមាគមទាំងអស់ ។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម ថា យ៉ាវ ដែលបានដឹកនាំសមាគមមន្ត្រីបុគ្គលិកយើងក្នុងរយៈពេល៤អណត្តិកន្លងមក បានទទួលជោគជ័យនិងបានបម្រើផលប្រយោជន៍រួម ចំពោះមន្ត្រីបុគ្គលិកយើង ។ ដើម្បីការងារនេះមាននិរន្តរភាព និងមានប្រសិទ្ធភាពថែមទៀត ខ្ញុំសូមសមាគមអាណត្តិទី៥នេះ បន្តការងារនិងពិនិត្យលទ្ធភាពជួយឧបត្ថម្ភមន្ត្រីបុគ្គលិក ពេលដែលមានការលំបាកជាពិសេស ត្រូវយកចិត្តទុកដាក់ពីបញ្ហាសុខភាព និងការលំបាកជាក់ស្តែងរបស់មន្ត្រីបុគ្គលិកបន្ថែមទៀត ។ ដើម្បីក្តាប់បានពីការលំបាក ទុក្ខធុរៈ និងស្ថានភាពរបស់មន្ត្រីបុគ្គលិកយើងធ្ងន់ឬស្រាល ខ្ញុំស្នើសុំឱ្យសមាគមបង្កើតឱ្យមានកម្មវិធីប្រជុំជីវភាពសមាជិកនៅតាមនាយកដ្ឋានឬអង្គភាពរបស់ខ្លួនជាទៀងទាត់ រួចរាយការណ៍មកគណៈកម្មាធិការសមាគមយើងប្រចាំខែ ។

**៨/- ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិក ៖** ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានជម្រាបជូនសមាជិកសមាជិកានៃអង្គសន្និបាតរួចហើយថា ការគ្រប់គ្រងធនធានមនុស្ស ការបណ្តុះបណ្តាលកម្លាំងបន្តវេន និងការធ្វើឯកទេសកម្មលើមុខជំនាញសម្រាប់គាំទ្រប្រតិបត្តិការធនាគារកណ្តាល គឺជាការងារសំខាន់សម្រាប់ស្ថាប័ន និង ប្រទេសជាតិ ព្រោះការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ យើងត្រូវបណ្តុះបណ្តាលមន្ត្រីលើផ្នែកជំនាញឯកទេសកម្ម ដើម្បីកសាងកម្លាំងបន្តវេន និងបន្តនិរន្តរភាពនិងស្ថិរភាពការងាររបស់យើងនៅពេលអនាគត ខណៈដែលថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិករបស់យើងកំពុងចូលនិវត្តន៍ជាបណ្តើរៗ ។ ការបណ្តុះបណ្តាល របស់យើងមានគ្រប់រូបភាព ទាំងនៅក្នុងនិងក្រៅប្រទេស លើផ្នែកជំនាញឯកទេសកម្មនិងផ្នែកគុណធម៌ ។

ក្នុងប្រទេស យើងបានរៀបចំក្រោមរូបភាពនៃការផ្ទេរនិងចែករំលែកចំណេះដឹង និងវគ្គបណ្តុះបណ្តាលផ្សេងៗ ។ នៅក្រៅប្រទេស យើងមានដៃគូអភិវឌ្ឍក្នុងតំបន់និងអន្តរជាតិដូចជា មជ្ឈមណ្ឌលបណ្តុះបណ្តាល IMF, ADB, WB, មជ្ឈមណ្ឌល SEACEN និង ASEAN និងការបណ្តុះបណ្តាលជាលក្ខណៈទ្វេភាគីជាមួយធនាគារកណ្តាលនៅតំបន់អឺរ៉ុប ដូចជាធនាគារកណ្តាលបារាំង អាល្លឺម៉ង់ និងលុចហ្សំបួរ ហើយនៅតំបន់អាស៊ី មានធនាគារកណ្តាល

ថៃ កូរ៉េ និងវៀតណាម ជាដើម ។ ជាលទ្ធផល យើងទទួលបានមន្ត្រីដែលមានសមត្ថភាពជំនាញជាបន្តបន្ទាប់និងបានជួយការងាររបស់យើងសម្រេចបានសមិទ្ធផលល្អប្រសើរ ។

ដើម្បីបន្តអនុវត្តការងារបណ្តុះបណ្តាលឱ្យកាន់តែល្អប្រសើរថែមទៀត ខ្ញុំស្នើសុំឱ្យអគ្គលេខាធិការដ្ឋានត្រូវរៀបចំយន្តការ និងកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ ជាពិសេស វគ្គបាគងស៊ីពីការត្រួតពិនិត្យធនាគារ និងវគ្គ Leadership ជូនដល់មន្ត្រីបុគ្គលិករបស់យើង ហើយសូមឱ្យមន្ត្រីបុគ្គលិកយើងខិតខំសិក្សារៀនសូត្របន្ថែម ដើម្បីដើរឱ្យទាន់សភាពការណ៍រីកចម្រើននៃសេដ្ឋកិច្ច និងមានភាពម្ចាស់ការក្នុងការគ្រប់គ្រងធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធ ធនាគារនៅកម្ពុជាឱ្យកាន់តែរីកចម្រើនថែមទៀត។

**៩/-ការពង្រឹងប្រតិបត្តិការជាមួយសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ៖** ត្រូវបានកែលម្អ និងកែសម្រួលឱ្យស្របតាមការអភិវឌ្ឍរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចក្នុខេត្តនេះ ។ ការងារសំខាន់ៗ និងជាគោលនយោបាយជំរុញការប្រើប្រាស់ប្រាក់រៀលរបស់យើង តាមរយៈការគ្រប់គ្រងសាច់ប្រាក់ ការសម្របសម្រួលការដាក់ឱ្យចរាចរសាច់ប្រាក់ ការធ្វើប្រតិបត្តិការផ្ទេរសាច់ប្រាក់ និងជាយន្តការជំរុញការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលផងដែរ ។ ដូច្នេះ ខ្ញុំសូមស្នើសុំឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ត្រូវពង្រឹងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងដែនដីរដ្ឋបាល ដើម្បីសម្រួលការដាក់ឱ្យចរាចរប្រាក់រៀលឱ្យប្រព្រឹត្តទៅដោយរលូននិងកាន់តែទូលំទូលាយថែមទៀត ។

**១០/- ការងារសហប្រតិបត្តិការអន្តរជាតិ :** ការងារនេះមានសារៈសំខាន់ណាស់ សម្រាប់ធនាគារជាតិនៃកម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការមិត្តភាព និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ និងការពង្រឹងប្រតិបត្តិការ ធនាគារកណ្តាល ។ កិច្ចសហប្រតិបត្តិការអន្តរជាតិ យើងមានការរីកចម្រើនយ៉ាងខ្លាំង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

ខ្ញុំស្នើសុំឱ្យមន្ត្រីបុគ្គលិកយើងបន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយប្រទេសជាមិត្ត ដើម្បីការងារបណ្តុះបណ្តាលជំនាញ ពង្រីកបណ្តាញការងារ និងលើកកម្ពស់សមត្ថភាពការងារបន្ថែមទៀត ។

- **គណៈអធិបតី**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

សរុបមក ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើនេះ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជាដែលយើងត្រូវអនុវត្តចំពោះមុខ រយៈពេលមធ្យមនិងវែង នៅពេលអនាគតដើម្បីពង្រឹងប្រព័ន្ធធនាគារទាំងមូលឱ្យប្រព្រឹត្តទៅដោយរលូននិងមានសុវត្ថិភាព ។ មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើនូវមតិមួយចំនួនដូចខាងក្រោម ៖

១/- ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅបន្តផ្សព្វផ្សាយ នៅតាមនាយកដ្ឋាន និងអង្គភាពរៀងៗខ្លួន នូវខ្លឹមសារនិងអនុសាសន៍ល្អៗ ដើម្បីអនុវត្តចំពោះការងារប្រចាំថ្ងៃ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត

២/- សូមមន្ត្រីបុគ្គលិករបស់យើងបន្តរក្សានូវស្មារតីសាមគ្គីគ្នាជាប្រពៃណី ដើម្បីបុព្វហេតុនៃការអភិវឌ្ឍធនាគារជាតិនៃកម្ពុជា ឱ្យទទួលបានជោគជ័យថ្មីៗបន្ថែមទៀត និង

៣/- បន្តអនុវត្តនូវ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យប្រព្រឹត្តទៅដោយប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មជាមួយប្រទេសក្នុងតំបន់និងពិភពលោក ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ធនាគារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិនិងអន្តរជាតិ ។ ដើម្បីសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាបន្តស្មារតីរួមសាមគ្គី សហការគ្នាជាប្រពៃណី និងទទួលខុសត្រូវចំពោះការងារ ដើម្បីរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗថែមទៀត និងកាន់តែមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**